នស/រកម/០២១១/០០៣

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់កែតម្រូវ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់កែតម្រូវ

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

**មាត្រា ១.-**

ត្រូវបានយល់ព្រមជាគោលការណ៍ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ឲ្យខ្ចីប្រាក់ពីគេបន្ថែមដូចខាងក្រោម :

- យល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែមទៀត មានកម្រិតរហូតដល់ ៣០.០០០.០០០ SDR ( សាមសិបលានអេសដេអ៊ែ ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។
- យល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែម មានកម្រិតរហូតដល់ ១៧០.០០០.០០០ SDR ( មួយរយចិតសិបលានអេសដេអ៊ែ ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា ២.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល. ១១០៧. ១៣៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

**លេខ:១៣៦ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឌិនកេន**

# កិច្ចព្រមព្រៀងឥណទានដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០០៩

| លរ | ឈ្មោះគម្រោង | ដៃគូអភិវឌ្ឍន៍ | ភ្នាក់ងារអនុវត្តគម្រោង | កាលបរិច្ឆេទ ចុះហត្ថលេខា | កាលបរិច្ឆេទ ចូលជាធរមាន | ឥណទាន (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|
| **ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** | | | | | | **29,660,000** |
| 1 | គម្រោងស្តាបនាឡើងវិញផ្លូវជាតិលេខ ៥៦ | ADB | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ១៧ ខែកញ្ញា ឆ្នាំ២០០៩ | ២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ | 16,260,000 |
| 2 | កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ជំហានទី២ អនុកម្មវិធីទី៣ | ADB | ធនាគារជាតិ នៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម | ២៧ ខែធ្នូ ឆ្នាំ២០០៩ | ២៥ ខែកុម្ភៈ ឆ្នាំ២០១០ | 10,000,000 |
| 3 | គម្រោងកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប | ADB | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ (លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) និង អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិជ្ជា គមនាគមន៍ ព័ត៌មានវិទ្យា | ២៧ ខែធ្នូ ឆ្នាំ២០០៩ | ៣១ ខែមីនា ឆ្នាំ២០១០ | 3,400,000 |
| **ធនាគារពិភពលោក (WB)** | | | | | | **5,000,000** |
| 1 | គម្រោងប្រតិបត្តិការគាំទ្រកសិកម្មខ្នាតតូច និង ការគាំពារសង្គម | WB | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និង ក្រសួងផែនការ | ០៤ ខែសីហា ឆ្នាំ២០០៩ | ១៥ ខែតុលា ឆ្នាំ២០០៩ | 5,000,000 |

| | | | | | | |
|---|---|---|---|---|---|---|
| **មូលនិធិសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិអូប៉ិក (OFID)** | | | | | | **7,000,000** |
| 1 | គម្រោងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | OFID | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ២៩ ខែមិថុនា ឆ្នាំ២០០៩ | ២២ ខែកញ្ញា ឆ្នាំ២០០៩ | 7,000,000 |
| **ដៃគូអភិវឌ្ឍន៍ទ្វេភាគី** | | | | | | **647,673,521** |
| 1 | គម្រោងផ្គត់ផ្គង់ទឹកស្អាតនិរោធ | ជប៉ុន | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ២៥ ខែមិនា ឆ្នាំ២០០៩ | ១៧ ខែកក្កដា ឆ្នាំ២០០៩ | 32,229,358 |
| 2 | គម្រោងអភិវឌ្ឍន៍ចំណតពហុបំណង កំពង់ផែក្រុងព្រះសីហនុ | ជប៉ុន | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២១ ខែសីហា ឆ្នាំ២០០៩ | ១០ ខែធ្នូ ឆ្នាំ២០០៩ | 74,132,231 |
| 3 | គម្រោងសាងសង់ស្ថានីយ៍បម្រោះទឹកកខ្វក់ និង អភិវឌ្ឍន៍ស្ទឹងសៀមរាប | កូរ៉េ | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ០៤ ខែមិថុនា ឆ្នាំ២០០៩ | ១៩ ខែសីហា ឆ្នាំ២០០៩ | 29,960,000 |
| 4 | គម្រោងកែលម្អកំណាត់ផ្លូវជាតិលេខ ៣១ ផ្លូវជាតិលេខ ៣៣ ផ្លូវខេត្តលេខ ១១៧ និងផ្លូវវាងខេត្តកំពត | កូរ៉េ | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ០៤ ខែមិថុនា ឆ្នាំ២០០៩ | ១៩ ខែសីហា ឆ្នាំ២០០៩ | 30,000,000 |
| 5 | គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ ៧៨ ពីអូពងមាន់ ខេត្តស្ទឹងត្រែង ទៅដល់ក្រុងបានលុង ខេត្តរតនគិរី | ចិន | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ១៨ ខែមិថុនា ឆ្នាំ២០០៩ | ០៩ ខែតុលា ឆ្នាំ២០០៩ | 75,113,235 |
| 6 | គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ ៦២ និង សាងសង់ផ្លូវបំបែកពីផ្លូវជាតិលេខ ៨ អន្លង់ជ្រៃ-ក្រែក និង ក្រចៅ-ម៉ឺនជ័យ | ចិន | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ២៣ ខែតុលា ឆ្នាំ២០០៩ | ០៩ ខែកុម្ភៈ ឆ្នាំ២០១០ | 64,944,964 |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | គម្រោងអភិវឌ្ឍន៍ធារាសាស្ត្រកង្ហត ក្នុងខេត្តបាត់ដំបង | ចិន | ក្រសួងធនធានទឹក និង ឧតុនិយម | ២៣ ខែតុលា ឆ្នាំ២០០៩ | ០៩ ខែកុម្ភៈ ឆ្នាំ២០១០ | 47,416,373 |
| 8 | គម្រោងសាងសង់បន្តផ្លូវជាតិលេខ ៧៦ សែនមនោរម្យ-ដាក់ដាំ | ចិន | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ២១ ខែធ្នូ ឆ្នាំ២០០៩ | ២២ ខែមីនា ឆ្នាំ២០១០ | 14,466,782 |
| 9 | គម្រោងការពារទឹកជំនន់ទន្លេកំពង់ត្របែក ខេត្តព្រៃវែង | ចិន | ក្រសួងធនធានទឹក និង ឧតុនិយម | ២១ ខែធ្នូ ឆ្នាំ២០០៩ | ២២ ខែមីនា ឆ្នាំ២០១០ | 29,463,746 |
| 10 | គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី នៅតាមតំបន់ជុំវិញរាជធានីភ្នំពេញ | ចិន | អគ្គិសនីកម្ពុជា (EDC) | ២១ ខែធ្នូ ឆ្នាំ២០០៩ | ០៦ ខែកញ្ញា ឆ្នាំ២០១០ | 75,870,000 |
| 11 | គម្រោងសាងសង់ផ្លូវជាតិលេខ៥៧ បេ ថ្មគោល-បវេល-សំពៅលូន/បវេល-ភូមិសាម សិប-ភ្នំព្រឹក/ភូមិសាមសិប-កំរៀង-អូរដា | ចិន | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ២១ ខែធ្នូ ឆ្នាំ២០០៩ | ២២ ខែមីនា ឆ្នាំ២០១០ | 92,139,520 |
| 12 | គម្រោងសាងសង់ផ្លូវជាតិលេខ៥៩ ប៉ៃលិន-កំរៀង-ភ្នំព្រឹក-សំពៅលូន-ម៉ាឡៃ-កូនដំរី | ចិន | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ២១ ខែធ្នូ ឆ្នាំ២០០៩ | ២២ ខែមិនា ឆ្នាំ២០១០ | 74,637,312 |
| 13 | កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច និង បច្ចេកទេស | ចិន | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ២១ ខែធ្នូ ឆ្នាំ២០០៩ | ២១ ខែធ្នូ ឆ្នាំ២០០៩ | 7,300,000 |
| | **សរុប** | | | | | **689,333,521** |

# កិច្ចព្រមព្រៀងឥណទានដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០១០

| ល.រ | ឈ្មោះគម្រោង | ដៃគូអភិវឌ្ឍន៍ | ភ្នាក់ងារអនុវត្ត | កាលបរិច្ឆេទចុះហត្ថលេខា | កាលបរិច្ឆេទចូលជាធរមាន | ឥណទាន (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|
| **ធនាគារអភិវឌ្ឍន៍អាស៊ី** | | | | | | **127,000,000** |
| 1 | គម្រោងស្តារឡើងវិញនូវប្រព័ន្ធផ្លូវដែកនៅកម្ពុជា (ហិរញ្ញប្បទានបន្ថែម) | ADB | កសដ | ០២ មីនា ២០១០ | ២១ មេសា ២០១០ | 42,000,000 |
| 2 | គម្រោងអភិវឌ្ឍន៍ការគ្រប់គ្រងវិស័យធនធានទឹក | ADB | ធទឧ | ២២ តុលា ២០១០ | | 10,000,000 |
| 3 | កម្មវិធីអភិវឌ្ឍន៍ការគ្រប់គ្រងវិស័យធនធានទឹក | ADB | ធទឧ | ២២ តុលា ២០១០ | | 20,000,000 |
| 4 | កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សម្រាប់អភិវឌ្ឍន៍ជនបទ អនុកម្មវិធីទី ២ | ADB | សហវ | ២២ តុលា ២០១០ | | 10,000,000 |
| 5 | គម្រោងកែលម្អផ្លូវលំជនបទ | ADB | កអជ | ២២ តុលា ២០១០ | | 35,000,000 |
| 6 | កម្មវិធីលើកកំពស់ពិពិធភាពសេដ្ឋកិច្ច អនុកម្មវិធីទី ២ | ADB | ក្រពាណិជ្ជកម្ម | ២២ តុលា ២០១០ | | 10,000,000 |
| **ធនាគារពិភពលោក និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD)** | | | | | | **38,200,000** |
| 1 | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប | IFAD | កសក- កមជ | ១៥ កុម្ភៈ ២០១០ | ៣១ មីនា ២០១០ | 6,700,000 |
| 2 | គម្រោងបង្កើនគុណភាព និងសមត្ថភាពអប់រំនៅកម្ពុជា | World Bank | អយក | ០៧ កញ្ញា ២០១០ | | 11,500,000 |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | គម្រោងស្តារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយព្យុះកេតសាណា | World Bank | កអជ | ១១ វិច្ឆិកា ២០១០ | | 20,000,000 |
| **ដៃគូអភិវឌ្ឍន៍ទ្វេភាគី** | | | | | | **139,507,824** |
| 1 | គម្រោងសាងសង់ខ្សែបញ្ជូនថាមពលអគ្គិសនីពីខេត្តក្រចេះដល់ខេត្តស្ទឹងត្រែង (ដំណាក់កាល ២) | ឥណ្ឌា | អគ្គិសនីកម្ពុជា | ០១ មីនា ២០១០ | ២៩ កក្កដា ២០១០ | 15,000,000 |
| 2 | គម្រោងកែលម្អផ្លូវជាតិនៅតាមខេត្តភាគពាយ័ព្យនៅកម្ពុជានៃមហាអនុតំបន់ទន្លេមេគង្គ | កូរ៉េ | កសដ | ០១ មិថុនា ២០១០ | ២៤ សីហា ២០១០ | 29,942,000 |
| 3 | គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងតាសាល (ដំណាក់កាល ២) | ឥណ្ឌា | ធទឧ | ១៤ កញ្ញា ២០១០ | | 15,000,000 |
| 4 | គម្រោងអភិវឌ្ឍន៍ធនធានទឹកព្រែកស្ទឹងកែវ ខេត្តកំពត | ចិន | ធទឧ | ០៤ វិច្ឆិកា ២០១០ | | 42,618,880 |
| 5 | គម្រោងសាងសង់ផ្លូវជាតិលេខ ៦១ | ចិន | កសដ | ២៧ តុលា ២០១០ | | 9,494,528 |
| 6 | គម្រោងពង្រីកកំពង់ផែភ្នំពេញ | ចិន | កំពង់ផែស្វយ័តភ្នំពេញ | ០៤ វិច្ឆិកា ២០១០ | | 27,452,416 |
| **សរុប** | | | | | | **304,707,824** |

**សំគាល់:**

កសដ : ក្រសួងសាធារណការ និងដឹកជញ្ជូន

កសក : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សហវ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ធទឧ : ក្រសួងធនធានទឹក និងឧតុនិយម

កមផ : ក្រសួងមហាផ្ទៃ

កអជ : ក្រសួងអភិវឌ្ឍន៍ជនបទ

អយក : ក្រសួងអប់រំ យុវជន និងកីឡា

# កិច្ចព្រមព្រៀងឥណទានដែលគ្រោងនឹងចុះហត្ថលេខាក្នុងឆ្នាំ ២០១០

| ល.រ | ឈ្មោះគម្រោង | ដៃគូអភិវឌ្ឍន៍ | ភ្នាក់ងារអនុវត្ត | កាលបរិច្ឆេទចុះហត្ថលេខា | កាលបរិច្ឆេទចូលជាធរមាន | ឥណទាន (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|
| ដៃគូអភិវឌ្ឍន៍ទ្វេភាគី | | | | | | 232,728,112 |
| 1 | គម្រោងសាងសង់ស្ពានជ្រោយចង្វារទី ២ | ចិន | ក្រសួងសាធារណការ និងដឹកជញ្ជូន | | | 26,752,000 |
| 2 | គម្រោងសាងសង់ស្ពានតាខ្មៅ និងផ្លូវទៅកាន់ស្ពាន | ចិន | ក្រសួងសាធារណការ និងដឹកជញ្ជូន | | | 31,995,392 |
| 3 | គម្រោងអភិវឌ្ឍន៍ទំនប់ស្ទឹងពោធិ៍សាត់ លេខ ៣ និងលេខ ៥ | ចិន | ក្រសួងធនធានទឹក និងឧតុនិយម | | | 63,134,720 |
| 4 | គម្រោងសាងសង់ផ្លូវជាតិលេខ ៤១ ពីថ្នល់ទទឹង ដល់ជុំគីរី | ចិន | ក្រសួងសាធារណការ និងដឹកជញ្ជូន | | | 44,992,000 |
| 5 | គម្រោងអភិវឌ្ឍន៍ទំនប់មង្គលបូរី | កូរ៉េ | ក្រសួងធនធានទឹក និងឧតុនិយម | | | 18,700,000 |
| 6 | គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកទន្លេសាបខាងលិច | ជប៉ុន | ក្រសួងធនធានទឹក និងឧតុនិយម | | | 47,154,000 |
| សរុប | | | | | | 232,728,112 |